# គណនេយ្យភាពនៅក្នុងកម្មវិធីការងារ : ករណីនៃសវនកម្មសង្គមនៅក្នុង NREGA

បរាជ័យនៃផែនការ និងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗគ្នាដើម្បីអនុវត្តគម្រោងដែលបានរៀបចំ និងនាំទៅដល់ការអភិវឌ្ឍដល់ដៃប្រជាជន។ ការកែទម្រង់អភិបាលកិច្ច និងអភិបាលកិច្ចល្អបានក្លាយជាចំណុចពិភាក្សាគ្នាជាទូទៅនៅក្នុងការអភិវឌ្ឍអាជីព និងការិយាធិបតេយ្យ សម្រាប់រយៈពេល១០ ឆ្នាំចុងក្រោយនេះ។ តម្លាភាព គណនេយ្យភាព និងការចូលរួម គឺជាសមាសភាពដ៏សំខាន់នៃអភិបាលកិច្ចល្អ។ ដូច្នេះកម្មវិធីដាក់ចេញនៅពេលថ្មីៗនេះ គឺបានបង្កើតនូវយន្តការសម្រាប់ជំរុញឱ្យមានតម្លាភាព គណនេយ្យភាព និងការចូលរួម។ (ច្បាប់ធានាដល់ការអវិឌ្ឍតំបន់ជនបទរបស់ជាតិ) (NREGA) សម្រាប់ឆ្នាំ២០០៥ គឺជាឧទាហរណ៍មួយនៃឧទាហរណ៍ទាំងឡាយ។

NREGA ផ្តល់រយៈពេល ១០០ថ្ងៃ នៃការងារដែលបានធានានៅក្នុងរយៈពេល១ឆ្នាំហិរញ្ញវត្ថុសម្រាប់គ្រួសារនៅជនបទទាំងអស់ដែលសមាជិកមានបំណងធ្វើការងារហត្ថកម្ម។ សកម្មភាពនោះមិនត្រឹមតែបានធានាឱ្យមានការងារដែលមានប្រាក់កម្រៃត្រឹមត្រូវប៉ុណ្ណោះ ទេ តែថែមទាំងជួយជំរុញការត្រួតពិនិត្យសហគមន៍តាមរយៈការប្រុងប្រយ័ត្ន និងគណៈកម្មាធិការ ត្រួតពិនិត្យសវនកម្មសង្គម តាមរយៈ Gram Sabha ហើយនិងធ្វើបទបញ្ញត្តិសម្រាប់តម្លាភាពពេញលេញ ដូចដែលបានកំណត់អាណត្តិដោយសិទ្ធិសារព័ត៌មាន ឆ្នាំ២០០៥ ផងដែរ។

នៅពេលបច្ចុប្បន្ននេះ (ផែនការធានាការអភិវឌ្ឍតំបន់ជនបទរបស់ជាតិ) (NREGS) បានគ្របដណ្តប់ស្រុកចំនួន៣៣០ នឹងពង្រីកទៅស្រុកទាំងអស់ចំនួន៦០០ ចាប់ពីឆ្នាំហិរញ្ញវត្ថុក្រោយទៅ (២០០៨-០៩)។ បរិមាណទឹកប្រាក់នៅពេលបច្ចុប្បន្ននៃ Rs. 12,000 Cr. ទំនងជាកើនឡើងដល់ទៅ Rs. 22,000 Cr។ កម្មវិធីការងារទទួលបានប្រាក់កម្រៃដែលមានទំហំប៉ុននេះអាចទទួលបានជោគជ័យ ប្រសិនបើ បទបញ្ញត្តិស្តីពីតម្លាភាព គណនេយ្យភាព និងការចូលរួមនៃសកម្មភាពត្រូវបានប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹង។

អង្គការរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលជាច្រើនបានសម្របសម្រួលដល់ដំណើរការសវនកម្មសង្គមនៅក្នុង NREGA ក្នុងរយៈពេល១ឆ្នាំ ចុងក្រោយនេះ។ ឯកសារនេះសាកល្បងស្វែងយល់វិធីសាស្ត្រ និងដំណើរការនៃសវនកម្មនោះ ហើយនិងវិភាគ ទៅលើច្រកចេញ និងបញ្ហា ដែលកើតឡើងចាំបាច់ត្រូវលើកឡើងផងដែរ។ ឯកសារនេះបានរៀបរាប់អំពីចំណុច បញ្ច្រាស់គ្នាចេញមកពីអន្តរាគមន៍របស់ UNNATI នៅ PRIA នៅ Himachal Pradesh, Jharkhand និង Rajasthan ។

## តម្រូវការសម្រាប់សវនកម្មសង្គម :

គោលដៅមូលដ្ឋាននៃសវនកម្មសង្គម គឺធានាគណនេយ្យភាពសាធារណៈ នៅក្នុងការអនុវត្តគម្រោង ច្បាប់ និងគោលនយោបាយ។ ទម្រង់សាមញ្ញមួយនៃសវនកម្មសង្គម គឺសន្និបាតជាសាធារណៈ ដែលបរិយាយពិស្តារអំពីគម្រោងទាំងអស់ត្រូវបានពិនិត្យពិច័យយ៉ាងហ្មត់ចត់។ ទោះបីជាយ៉ាងនេះក្តី "សវនកម្មសង្គម " អាចត្រូវបានស្វែងយល់កាន់តែទូលំទូលាយថាជាដំណើរការបន្តនៃការអង្កេតតាមដានជាសាធារណៈ។

ដូច្នេះហើយ សវនកម្មសង្គម ត្រូវបានមើលឃើញថាជាមធ្យោបាយមួយក្នុងការជំរុញបទដ្ឋានមូលដ្ឋានទាំងឡាយខាងក្រោមនេះ នៅបញ្ហាជាសាធារណៈ :

- **តម្លាភាព :** តម្លាភាពពេញលេញនៅក្នុងដំណើរការរដ្ឋបាល និងការធ្វើការសម្រេចចិត្ត ជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋាភិបាល ចំពោះ *suo moto* ដើម្បីផ្តល់ឱ្យប្រជាជននូវសិទ្ធិទទួលបានពេញលេញនូវព័ត៌មានពាក់ព័ន្ធទាំង អស់។
- **ការចូលរួម :** ជាការផ្តល់សិទ្ធិសម្រាប់មនុស្សដែលបានទទួលគម្រោង (ហើយមិនត្រឹមតែអ្នកតំណាងរបស់ពួកគេប៉ុណ្ណោះទេ) ដើម្បីចូលរួមនៅក្នុងដំណើរការនៃការធ្វើការសម្រេចចិត្ត និងការផ្តល់សុពលភាព។
- **ការប្រឹក្សា និងការយល់ព្រម :** នៅក្នុងករណីដ៏កម្រទាំងអស់នោះ សិទ្ធិជ្រើសរើសត្រូវបានកំណត់ជាមុនក្រៅពីករណីចាំបាច់ សិទ្ធិរបស់មនុស្សដែលទទួលបានគម្រោងដើម្បីផ្តល់ការយល់ព្រមដែលបានជូនដំណឹង ជាក្រុម ឬជាបុគ្គលទៅតាមភាពសមស្រប។
- គណនេយ្យភាព : ទំនួលខុសត្រូវរបស់តំណាងដែលបានបោះឆ្នោតជ្រើសរើស និងមន្ត្រីរដ្ឋាភិបាល ក្នុងការឆ្លើយទៅនឹងសំណួរ និងផ្តល់ការបកស្រាយអំពីសកម្មភាពពាក់ព័ន្ធ និងភាពអសកម្ម ចំពោះមនុស្សពាក់ព័ន្ធ និងអ្នកដែលទទួលបានគម្រោង។
- ការកែតម្រូវឡើងវិញ : គឺជាបទដ្ឋានដែលតាមរយៈលទ្ធផលរកឃើញរបស់សវនកម្មសង្គម និងការស៊ើបអង្កេតជាសាធារណៈដទៃទៀត ដែលទទួលបានសច្ចាប័នជាផ្លូវការ ទទួលបានទិន្នផលសំខាន់ៗ និងត្រូវបានរាយការណ៍ត្រឡប់ទៅប្រជាជន វិញ អមទៅដោយព័ត៌មានស្តីពីវិធានការដែលបានចាត់ឡើងជាការឆ្លើយតបទៅនឹងតម្រូវការ។

NREGS គឺជាកម្មវិធីដែលផ្អែកលើតម្រូវការ និងជោគជ័យរបស់ខ្លួន ដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើថាតើវាមានភាពទាក់ទាញប៉ុណ្ណា ចំពោះប្រជាជនក្រីក្រដែលត្រូវការការងារនោះ។ ប្រសិនបើ គេមិនអនុវត្តតាមដំណើរការទេនោះ វានឹងនាំទៅរកភាពអវិជ្ជមាននៃការធានា និងការបើកប្រាក់មិនគ្រប់គ្រាន់ និងមិនទាន់ពេលវេលា ឬ កំណត់ត្រា និងបញ្ជីឈ្មោះសរុប ត្រូវបានគេបោកបញ្ឆោតដើម្បីទទួលបានផលប្រយោជន៍ជាលក្ខណៈបុគ្គល គោលបំណងពីរ នៃការងារ

ទទួលបានប្រាក់កម្រៃ និងការបង្កើតទ្រព្យធនសហគមន៍ទៅតាមផលិតភាព មិនអាច សម្រេចបាននោះទេ ដោយហេតុថា ប្រជាជននឹងនៅតែស្ថិត នៅឆ្ងាយពីវាយ៉ាងខ្លាំង។

ជោគជ័យនៅក្នុងការបង្កើតទ្រព្យធនសហគមន៍តាមផលិតភាព និងមានផលប្រយោជន៍ដែលអាចជួយលើក ស្ទួយជីវភាពរស់នៅនៅតាមតំបន់ជនបទមិនអាចធ្វើទៅបានដោយមិនមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងការរៀបចំ ផែនការ ការអនុវត្ត និង ការវាយតម្លៃការងារនោះទេ។ ហើយការចូលរួមនេះ អាចធ្វើទៅបានតែនៅពេលដែលដំណើរការមានតម្លាភាព ហើយអាជ្ញាធរទទួលខុសត្រូវក្នុងការសម្រួលការងារដល់ដល់ប្រជាពលរដ្ឋប៉ុណ្ណោះ។

**និយមន័យនៃសវនកម្មសង្គម :**

ទស្សនៈ នៃ "សវនកម្មសង្គម" ត្រូវបានដកស្រង់ចេញពីទស្សនៈនៃ "ទំនួលខុសត្រូវសង្គម (CSR)" ទ្រទ្រង់ ដោយអង្គភាពចូលរួម នៅជុំវិញពិភពលោក ដែលសវនកម្មសង្គមសំដៅទៅលើសវនកម្មនៃតួនាទីទទួលខុសត្រូវផ្នែកសង្គមដែលអនុវត្តដោយអង្គភាពចូលរួម។ សវនកម្មសង្គម គឺជាដំណើរការដែលបរិយាយពិស្តារអំពីធនធាន ទាំងធនធានហិរញ្ញវត្ថុ និងធនធានមិនមែនហិរញ្ញវត្ថុ ដែលប្រើប្រាស់ដោយ ភ្នាក់ងាសាធារណៈសម្រាប់គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ត្រូវបានរួមចំណែកជាមួយប្រជាជន ជាទូទៅ តាមរយៈវេទិការបស់សាធារណជន ដូចជា Gram Sabha នៅតំបន់ជនបទ ប្រទេសឥណ្ឌា។ សវនកម្មសង្គមអាចឱ្យប្រជាពលរដ្ឋពង្រឹង គណនេយ្យភាព និងតម្លាភាព ដោយផ្តល់ឱ្យអ្នកប្រើប្រាស់ជាក់ស្តែងនូវឱកាសពិនិត្យពិច័យទៅលើគំនិតផ្តួចផ្តើមអភិវឌ្ឍន៍។ និយាយឱ្យទូលំទូលាយទៅ ដំណើរការនៃសវនកម្មសង្គមមានសមាសភាពដូចខាងក្រោមនេះ : ក) លទ្ធភាពទទួលព័ត៌មាន/បរិយាយ ពិស្តារអំពីធនធាន ធនធានហិរញ្ញវត្ថុ និងធនធានមិនមែនហិរញ្ញវត្ថុ ដែលប្រើប្រាស់ដោយភ្នាក់ងារសាធារណៈសម្រាប់គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ , ខ) ការរៀបចំ អ្នកប្រើប្រាស់ជាក់ស្តែង/អ្នកទទួលផលពីគម្រោង/ប្រជាពលរដ្ឋ , គ) ការពិនិត្យពិច័យព័ត៌មានដែលផ្តល់ដោយអ្នកប្រើប្រាស់ជាក់ស្តែង។

នៅក្នុងប្រទេសឥណ្ឌា សវនកម្មសង្គមនៅក្នុងទម្រង់នៅពេលបច្ចុប្បន្ននេះ ត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយ Mazdoor Kisan Shakti Sangathan (MKSS)[1] ដើម្បីតាមដានអំពើពុករលួយទ្រង់ទ្រាយដ៏ធំ នៅក្នុងការងារជួយសម្រាលគ្រោះរាំងស្ងួត នៅ Rajasthan នៅពាក់កណ្តាលទសវត្សរ៍ ១៩៩០។

**បទបញ្ញត្តិសវនកម្មសង្គមនៅក្រោម** NREGA :

[1] MKSS ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩០ ដើម្បីពង្រឹងដំណើរការចូលរួម និងធ្វើការជាមួយពលករ និងកសិករនៅតាមភូមិ នៅ Central Rajasthan។ MKSS បានរៀបចំ (សវនការជាសារធារណៈ) ជាទម្រង់នៃការធ្វើសវនកម្ម។

មាត្រា ១៧ (១) និយាយថា Gram Sabha នឹងត្រួតពិនិត្យការងារទាំងអស់ដែលបានអនុវត្តនៅ Gram Panchayat ។ មាត្រា ១៧ (២) នៃ NREGA និយាយថា " Gram Sabha ត្រូវរៀបចំសវនកម្មសង្គមនៃគម្រោងទាំងអស់ជាទៀងទាត់នៅក្រោមផែនការដែលរៀបចំឡើងនៅ Gram Panchayat " ។ មាត្រា ១៧ (៣) និយាយថា " Gram Panchayat ត្រូវរៀបចំឯកសារទាំងអស់ ដោយរាប់បញ្ចូលទាំងបញ្ជីចុះឈ្មោះសរុប វិក្កយបត្រ សក្ខីបត្រ សៀវភៅវាស់វែង ឯកសារថតចម្លងនៃ ថានានុក្រមសច្ចាប័ន និងសៀវភៅគណនី និងឯកសារភ្ជាប់ទៅ Gram Sabha សម្រាប់គោលបំណងក្នុងការរៀបចំសវនកម្មសង្គម ។

គោលការណ៍ណែនាំប្រតិបត្តិការនៅថ្នាក់កណ្តាលដែលចេញដោយក្រសួងអភិវឌ្ឍន៍ជនបទរបស់សហភាព រដ្ឋាភិបាលរបស់ប្រទេស ឥណ្ឌា លើកឡើងសវនកម្មសង្គមជាបន្ត ព្រមទាំងសវនកម្មសង្គមរៀងរាល់ ៦ខែ តាមរយៈ Gram Sabha គេហៅថា "វេទិកាសវនកម្មសង្គម " ។ រដ្ឋបាលតាមរដ្ឋមួយចំនួន ជាឧទាហរណ៍ រដ្ឋបាល Rajasthan ក៏បានចេញគោលការណ៍ណែនាំ ឬ សៀវភៅដែលសរសេរ ពីសវនកម្មសង្គម ។

ដំណើរការសវនកម្មជាតិដោយផ្អែកលើគោលការណ៍ណែនាំគួរតែរាប់បញ្ចូលទាំងការយកចិត្តទុកដាក់ និងការពិនិត្យបញ្ជាក់របស់សាធារណជនដែលមានដំណាក់កាលអនុវត្តរបស់ NREGS ចំនួន១១ ខាងក្រោម : ការចុះបញ្ជីគ្រួសារ ការចែកចាយប័ណ្ណការងារ វិក្កយបត្រដាក់ពាក្យសុំការងារ ការរៀបចំលំដាប់ថ្នាក់នៃគម្រោង និងការជ្រើសរើសទីកន្លែង ការអភិវឌ្ឍ និងការឯកភាពទៅលើការ វាយតម្លៃបច្ចេកទេស និងការប្រកាសបទបញ្ជាការងារ ការបែងចែកការងារទៅឱ្យបុគ្គលការអនុវត្ត និងការគ្រប់គ្រងការងារ ការបើកប្រាក់ឧបត្ថម្ភដល់អ្នកដែលគ្មានការងារធ្វើ ការបើកប្រាក់កម្រៃ ការវាយតម្លៃការងារ សវនកម្មសង្គមទៅតាមអាណត្តិ នៅក្នុង Gram Sabha (វេទិកាសវនកម្មសង្គម) ។ គោលការណ៍ណែនាំបានកត់ត្រានូវលទ្ធភាពងាយរងគ្រោះជាច្រើន នៅដំណាក់កាល នីមួយៗ ផ្តល់អនុសាសន៍លើជំហានដើម្បី លើកកម្ពស់តម្លាភាព និងគណនេយ្យភាព ។ គោលការណ៍ណែនាំក៏បានពណ៌នានូវភាព ពិស្តារយ៉ាងខ្លាំង នូវវិធីផ្សព្វផ្សាយ និងប្រមូលទិន្នន័យ និងរៀបចំឯកសារ និងនីតិវិធីត្រូវអនុម័ត និងរបៀបវារៈទាក់ទងនឹង អាណត្តិរបស់ Gram Sabha សម្រាប់សវនកម្មសង្គម ។

សំអាងទៅលើបទបញ្ញត្តិនៃសកម្មភាព និងគោលការណ៍ណែនាំ ក្រសួងរបស់សហភាពក៏បានដាក់ចេញនូវសារាចរ និងទម្រង់ចំពោះរដ្ឋផ្សេងៗគ្នា ដើម្បីរៀបចំនូវសវនកម្មសង្គមរៀងរាល់៦ខែ ។ ក្រសួងកំពុងដំណើរការចេញគោលការណ៍ណែនាំដោយឡែកពីគ្នាសម្រាប់សវនកម្មនៅក្នុង NREGA ។

**អ្នកអនុវត្តសកម្មភាព និងវិធីសាស្ត្រផ្សេងគ្នា :**

ច្បាប់ គោលការណ៍ណែនាំ សារាចរ បានផ្តល់នូវគម្រោងការស្ថាប័ន និងបង្កើតនូវទីកន្លែងជាចន្លោះសម្រាប់សហគមន៍ក្នុងការ ចូលរួម នៅក្នុងការធានារតម្លាភាព និងគណនេយ្យភាព។ ទោះបីជាយ៉ាងនេះក្តី ដើម្បីធ្វើឱ្យគម្រោងការនេះមានដំណើរការ និងប្រកបដោយប្រសិទ្ធភាព គឺត្រូវការសម្របសម្រួលមួយចំនួនជាចាំបាច់។ នៅក្នុងរដ្ឋមួយចំនួនការសម្របសម្រួល នេះមិនត្រូវបានធ្វើឡើងដោយ ភ្នាក់ងាររដ្ឋាភិបាលដោយខ្លួនឯងនោះទេ គឺធ្វើដោយអង្គការសង្គមស៊ីវិលផ្សេងៗ និងដោយ ស្ថាប័នសិក្សា និងស្រាវជ្រាវផ្សេងៗ។

វិធីសាស្ត្រផ្សេងគ្នា ដើម្បីរៀបចំសវនកម្មសង្គមត្រូវបានធ្វើការអង្កេត។ វិធីសាស្ត្រទីមួយនៃវិធីសាស្ត្រទាំងឡាយគឺធ្វើវានៅក្នុងទម្រង់ យុទ្ធនាការដោយបញ្ចូលវាជាមួយនឹងកម្មវិធីយល់ដឹងដែលប្រតិបត្តិដោយភូមិ តំបន់ ឬចែកតាមថ្នាក់ស្រុក។ ឧទាហរណ៍ សវនកម្មសង្គមដ៏ធំរបស់ Dungarpur, Rajasthan នៅខែមេសា ឆ្នាំ២០០៦។ ការសិក្សាពីបទពិសោធន៍របស់ Dungarpur នៅក្នុងអង្គការក្រៅរដ្ឋាភិបាលចំនួន ៣១ របស់ Andhra Pradesh និងបណ្តាញ CSO រួមគ្នាជាមួយនាយកដ្ឋានអភិវឌ្ឍន៍ជនបទនៅក្នុងស្រុក Anantapur ដើម្បីរៀបចំ សវនកម្មសង្គមដ៏ធំមួយតាមរយៈ padayatra នៅខែសីហា ឆ្នាំ២០០៦ (CEC, 2006)។

វិធីសាស្ត្រទី២ ភាគច្រើន គឺសម្របសម្រួលដោយភ្នាក់ងាររដ្ឋាភិបាល ដើម្បីប្រមូលព័ត៌មានស្តីពីមូលដ្ឋានទម្រង់ដែលរៀបចំឡើងសម្រាប់ Gram Panchayats ទាំងអស់របស់ស្រុក។ នៅពេលនោះ របាយការណ៍ទាំងអស់ត្រូវបានអាននៅ Gram Sabha ហើយក៏បានធ្វើឱ្យមានសាមគ្គីភាពនៅតាមតំបន់ និងថ្នាក់ស្រុក ដើម្បីបញ្ជូនទៅអាជ្ញាធរថ្នាក់ខ្ពស់។ នៅក្នុងរដ្ឋបាលនៃរដ្ឋ Jharkhand បានអនុម័តវិធីសាស្ត្រនេះ (PRIA, 2007)។

វិធីសាស្ត្រទី៣ ដែកជាទូទៅសម្រសម្រួលដោយអង្គការសង្គមស៊ីវិល គឺត្រូវបានធ្វើឡើងដោយ Gram Panchayats ដែលបាន ជ្រើសរើស និងតំបន់ និងទិន្នន័យដែលប្រមូលបាន ជាមួយនឹងជំនួយរបស់អ្នកស្ម័គ្រចិត្ត មួយផ្នែកធំពីអ្នកខាងក្រៅ និងបាន ធ្វើបទបង្ហាញនៅតាម តំបន់ និងសវនការជាសាធារណៈនៅថ្នាក់ស្រុក ដែលចូលរួមដោយមន្ត្រីរដ្ឋាភិបាល។ វិធីសាស្ត្រនេះ ត្រូវ បានអនុម័តដោយ ASHA, MKSS, Jean Derez ។ល។ នៅអំឡុងពេលសវនកម្មសង្គមនៅ UP, Jharkhand, Chhattisgarh, Rajasthan ។ល។ (របាយការណ៍ពី ASHA, MKSS និងសិទ្ធិយុទ្ធនាការស្បៀងអាហារ)។

វិធីសាស្ត្រទី៤ ដែលផ្តួចផ្តើមបង្កើតឡើងដោយ Gram Panchayats ត្រូវបានសម្របសម្រួលដោយអង្គការសង្គមស៊ីវិលមួយចំនួន ដែលគណៈកម្មាធិការដែលមានប្រជាពលរដ្ឋ របស់ Gram Panchayats ប្រមូលព័ត៌មានហើយធ្វើបទបង្ហាញនៅក្នុង Gram Sabha រដ្ឋបាល Rajasthan នៅក្នុងគោលការណ៍ណែនាំរបស់ខ្លួន បានអនុម័ត

វិធីសាស្ត្រនេះ។ PRIA ក៏បានអនុម័តវិធីសាស្ត្រ នេះផងដែរនៅក្នុងចំណោមប្រជាជន Gram Panchayats ទាំងអស់នោះផងដែរ ដែលវាកំពុងដំណើរការដោយបង្ខំ (PRIA, 2007)។

***សវនកម្មសង្គមនៅក្នុង** Sabharkantha:* ដៃគូរបស់ PRIA គឺ Unnati បានចូលរួមនៅក្នុងការជំរុញអភិបាលកិច្ចដែលបានធ្វើវិមជ្ឈការ តាមរយៈការកសាងសមត្ថភាពរបស់ស្ថាប័នស្វ័យអភិបាលកិច្ច នៅក្នុងតំបន់នៅ Khedbrahma Taluka (block) របស់ស្រុក Sabharkantha នៃ Gujara តាំងពីឆ្នាំ២០០៣ មក។ តាំងពីឆ្នាំ២០០៦ នៅពេលដែល NREGA ចូលជាធរមាន Unnati បានជ្រើសរើសប្រជាជន Gram Panchayats ៥នាក់ : Dantral, Delwada, Chikhla, Paroya និង Didhiya សម្រាប់ការធ្វើអន្តរាគមន៍បន្ទាន់សំដៅ ធ្វើឱ្យប្រជាជន Panchayats មានលទ្ធភាពអនុវត្ត NREGS ប្រកបដោយប្រសិទ្ធភាព។ អន្តរាគមន៍នេះ គឺជាការបង្កើតនូវការតវ៉ា តាមរយៈ ការយល់ដឹង ការតម្រង់ទិសអ្នកដឹកនាំរបស់ប្រជាពលរដ្ឋ ការកសាងសមត្ថភាពរបស់អ្នកតំណាងដែលបានបោះឆ្នោត ជ្រើសរើស និងគណៈកម្មាធិការតាមដាន និងត្រួតពិនិត្យ និងសវនកម្មសង្គម។

Unnati បានអនុម័តគោលការណ៍ណែនាំដូចខាងក្រោមសម្រាប់សវនកម្មសង្គមនៅក្នុងចំណោមប្រជាជន Gram Panchayats ទាំងអស់ នេះ : ទី១ ប្រជាជន Gram Panchayats គួរតែមានដំណើរការផ្ទាល់ខ្លួន និងគ្រប់គ្រង Gram Sabha ទី២ ដំណើរការគួរតែមានភាពសាមញ្ញ និងអាចអនុវត្តបាន ទី៣ សវនកម្មគួរតែគ្មានការគំរាមកំហែង ប៉ុន្តែផ្តល់អំណាចឱ្យប្រជាជន ទី៤ ទំនាក់ទំនងស្អិតរមួតជាមួយ រដ្ឋបាល ដើម្បីសម្របសម្រួលស្ថាបនាកម្មនៃដំណើរការ។

ក្នុងអំឡុងពេលនៃការតម្រង់ទិសអ្នកដឹកនាំប្រជាពលរដ្ឋ គណៈកម្មាធិការតាមដាន និងត្រួតពិនិត្យ និងអ្នកតំណាងដែលបានបោះឆ្នោតជ្រើសរើស Taluka Nirikshan Samiti ត្រូវបានបង្កើតឡើង។ ទស្សនៈនៃសវនកម្មសង្គមត្រូវបានណែនាំនៅក្នុងកិច្ចប្រជុំរបស់ Taluka Nirikshan Samiti ។ Sarpanchs (ប្រធាន) របស់ Dantral, Didhiya និង Paroya Gram Panchayats បានស្ម័គ្រចិត្តផ្តួចផ្តើមបង្កើត និងធ្វើការចាត់ចែងការងារសំខាន់ៗ សម្រាប់ Gram Sabhas ។

.

អភិបាលខេត្ត និងលេខា អ្នកសម្របសម្រួលផ្នែកអភិវឌ្ឍន៍ជនបទ និងគម្រោងរបស់រដ្ឋ សម្រាប់ NREGS ត្រូវបានដាក់បញ្ចូល ហើយពួកគាត់បានណែនាំអ្នកសម្របសម្រួលកម្មវិធីស្រុក (DPC) ដើម្បីទ្រទ្រង់ដល់ការផ្តួចផ្តើមគំនិតនៅពេលដំណើរការអប់រំនោះ ហើយក៏ចូលរួមជាមួយ Gram Sabhas ទាំងអស់ផងដែរ។

មានការប្រឹក្សាក្រៅផ្លូវការជាច្រើនជាមួយប្រជាជន Gram Panchayats ហើយពួកគាត់ត្រូវបានផ្តល់នូវការគាំទ្រ hand-holding នៅក្នុងបង្ហាញនូវសេចក្តីជូនដំណឹងសម្រាប់ Gram Sabha ដោយជូនដំណឹងដល់ប្រជាពលរដ្ឋ ហើយក៏បើកចំហកំណត់ត្រាទាំងអស់ទៅសាធារណជនផងដែរ។ អ្នកដឹកនាំសហករណ៍ប្រជាពលរដ្ឋថ្នាក់ភូមិ 'Panchayat Vikas Samiti'

បានដើរតួនាទីសំខាន់។ ខ្សែភាពយន្តដែលមានរយៈពេល ១៥នាទី បង្ហាញអំពីសវនកម្មសង្គមត្រូវបានប្រើដើម្បីបង្កើនការយល់ដឹង បញ្ជាក់នូវចម្ងល់ និងលើក យកបញ្ហារបស់ប្រជាជន នៅមុនពេលធ្វើកាលវិភាគ Gram Sabha សម្រាប់សវនកម្មសង្គម។

ការបង្រៀនជំនាញរដ្ឋ ដែលបានជួយនៅក្នុងការប្រមូលផ្តុំការគាំទ្ររបស់មន្ត្រី នៅថ្នាក់ស្រុក តំបន់ និងថ្នាក់ភូមិ នៅក្នុងការធ្វើលទ្ធកម្ម ព័ត៌មានដែលត្រូវការ។ អ្នកស្ម័គ្រចិត្តលេខា Gram Panchayat (Talati) ដើម្បីចងក្រងព័ត៌មានដែលពាក់ព័ន្ធនឹងការងារ។ ទិន្នន័យដែលបានចងក្រងទាំងនេះត្រូវបានវិភាគ ហើយបន្ទាប់ពីការវិភាគ វាត្រូវបានកំណត់ថា នៅត្រូវការព័ត៌មានមួយចំនួនបន្ថែមទៀត។ ការបកស្រាយមួយចំនួនពីមន្ត្រីកម្មវិធីក៏ត្រូវការចាំបាច់ផងដែរ។

នៅក្នុងកិច្ចប្រជុំជាមួយអ្នកដឹកនាំ Gang និងកម្មករ ទិន្នន័យទាំងនៅត្រូវបានត្រួតពិនិត្យ។ គ្រួសារដែលនៅដោយឡែកពីគេ ក៏ត្រូវបានចុះទៅមើលផងដែរ។ ការដ្ឋានការងារ និងទ្រព្យសកម្មដែលបានបង្កើតឡើងត្រូវបានចុះពិនិត្យមើលសម្រាប់ការត្រួតពិនិត្យជាក់ស្តែង។

ការធ្វើកំណែនសហគមន៍សម្រាប់ Gram Sabha ត្រូវបានធ្វើឡើង តាមរយៈ កិច្ចប្រជុំ falia (locality), ក្រុមជួយខ្លួនឯង។ ការសិក្សាពីព័ត៌មានដែលបានវិភាគទៅលើបទពិសោធន៍ បានចែករំលែកជាមួយសហគមន៍បានយ៉ាងល្អ នៅមុនពេល Gram Sabha ដើម្បីធ្វើ ឱ្យពួកគាត់មានលទ្ធភាពលើកឡើងនូវបញ្ហា។ ព័ត៌មានទាំងនេះត្រូវបានបង្ហាញនៅលើជ្យាក្រាមដើម្បីឱ្យមានការងាយស្រួលយល់ទម្រង់នោះ។

នៅថ្ងៃមុនពេល Gram Sabha គ្រួសារក្រីក្រ និងរស់នៅដោយឡែកពីគេត្រូវបានចុះទៅសួរសុខទុក្ខ ដើម្បីជួយជំរុញទំនុកចិត្តរបស់ ពួកគាត់។ ការពិភាក្សាទៅលើកាលវិភាគ និងព័ត៌មានចុងក្រោយដែលបានចែករំលែកនៅក្នុង Gram Sabha Sarpanch និង Talati។ ស្ត្រី Sarpach (ប្រធាន) របស់ Chikhla និង Paroya ត្រូវការជួយជំរុញផ្នែកស្មារតី។

នៅថ្ងៃមុន Gram Sabha ចម្រៀងលើកទឹកចិត្តអំពី NREGS និងសវនកម្មសង្គមត្រូវបានច្រៀងដោយអ្នកស្ម័គ្រចិត្ត។ កិច្ចប្រជុំដែលបានរៀបចំឡើងដោយ gram mitra អ្នកដឹកនាំប្រជាពលរដ្ឋ ឬ ជាគ្រូបង្រៀននៅសាលាបឋមសិក្សា។ Talati បានធ្វើបទបង្ហាញ ទិន្នន័យដែលពាក់ព័ន្ធនឹងការចុះបញ្ជី ប័ណ្ណការងារ លំដាប់ថ្នាក់គម្រោង ថវិកាដែលបានធ្វើសច្ចាប័នការងារដែលបានធ្វើ ចំនួនថ្ងៃធ្វើការរបស់មនុស្ស ។ល។ អ្នកដឹកនាំប្រជាពលរដ្ឋអានព័ត៌មានពីចំណុចចាប់ផ្តើមដែលកើតឡើងនៅកន្លែងធ្វើការ។ ការពិនិត្យបញ្ជីឈ្មោះ សរុបដែលមិនច្បាស់លាស់ត្រូវបានធ្វើឡើង ហើយបន្ទាប់មក កិច្ចប្រជុំគឺទុកចំហសម្រាប់ការសួរសំណួរ ឬ បញ្ហារបស់សមាជិក។ អ្នកសម្របសម្រួលកម្មវិធីថ្នាក់ស្រុកបន្ថែម (ADPC) បានសន្យា

បង្កើតវិធានការសមស្របនៅចំពោះការតវ៉ាដែលមានសុពលភាព។ Gram Sabha ត្រូវបានប្រើប្រាស់ដើម្បីជម្រះចម្ងល់អំពីបទបញ្ញត្តិ និងនីតិវិធីនៅក្រោម NREGS ។

**ជំហាននានានៃសវនកម្មសង្គម :**

អ្នកដែលបានដឹកនាំសវនកម្មសង្គមគឺជាការប្រឈមមុខដ៏ស្មុកស្មាញ ហើយទាមទារឱ្យមានជំហានជាច្រើនដើម្បីអនុវត្ត។ សារៈសខាន់ក្នុងចំណោមជំហានទាំងនោះរួមមានដូចខាងក្រោម:

១. **ការបង្កើតបរិស្ថាន :** ជាបឋម ហើយជាចាំបាច់នោះគឺបរិស្ថានដែលមានសារៈប្រយោជន៍នៅឯ Gram Panchayats គឺចាំបាច់ត្រូវបង្កើតឡើង។ ការប្រឹក្សាជាមួយអ្នកតំណាងដែលត្រូវបានជ្រើសរើស សមាជិកនៃគណៈកម្មាធិការឃ្លាំមើល និងត្រួតពិនិត្យតាមដាន ក្រុមស្ត្រី និងយុវជន និងមន្ត្រីនានា ត្រូវធ្វើឡើងដើម្បីបណ្តុះទស្សនវិស័យជារួមទៅលើសារៈសំខាន់នៃសវនកម្មសង្គមក្នុងការអនុវត្តដែលមានប្រសិទ្ធភាពទៅលើ NREGS និងអភិបាលកិច្ចល្អ។ ក្នុងករណីភាគច្រើនគឺ អ្នកតំណាងដែលត្រូវបានជ្រើសរើស ប្រធានទើបកាន់តំណែងថ្មីៗ និងមន្ត្រីនានានៅពេលដំបូងតែងតែមានអារម្មណ៍ភ័យខ្លាច ហើយមិនចង់ចូលរួម។ ដូច្នេះហើយបរិស្ថានដែលមិនមានការគំរាមកំហែងមួយ ចាំបាច់ត្រូវតែបង្កើតឡើងដែលនាំឱ្យប្រធានទើបតែងតាំងថ្មី និងមន្ត្រីនានានៃ Gram Panchayats អាចធ្វើជាម្ចាស់លើដំណើរការនេះបាន។ មន្ត្រី NREGS ថ្នាក់រដ្ឋ និងថ្នាក់ស្រុកត្រូវបានចូលរួមចាត់តាំងពីការចាប់ផ្តើម ហើយពួកគេអាចគ្រប់គ្រងទៅលើផ្នែក និងមន្ត្រីថ្នាក់ GP ឱ្យធ្វើសហប្រតិបត្តិការដោយឈរជាផ្នែកមួយនៃដំណើរការនេះ។

២. **ទម្រង់បែបបទនៃគណៈកម្មាធិការ :** ក្នុងអំឡុងពេលនៃការខិតខំប្រឹងប្រែងក្នុងការបង្កើតបរិស្ថានពលរដ្ឋដែលសកម្ម ស្មោះត្រង់ និងដែលចេះគោរពប្រតិបត្តិ គឺចាំបាច់ត្រូវបានកំណត់។ អ្នកដែលត្រូវបានចាប់អារម្មណ៍ក្នុងចំណោម សមាជិកនៃគណៈកម្មាធិការឃ្លាំមើល និងត្រួតពិនិត្យតាមដាន អ្នកតំណាងនៃក្រុមស្ត្រី ក្រុមយុវជន CBOដែលមកពី Gram Panchayat ផ្ទាល់តែម្តងនឹងបង្កើតគណៈកម្មាធិការមួយសម្រាប់ធ្វើសវនកម្មសង្គម។ ប្រសិនបើរដ្ឋាភិបាលបានផ្តល់ឱ្យ នូវការណែនាំមួយចំនួនសម្រាប់ជាច្បាប់កំពូលនៃគណៈកម្មាធិការនេះហើយនោះការណែនាំទាំងនោះត្រូវតែជាការណែនាំដែល ស្របជាមួយនឹងដំណើរការនេះ។ នៅក្នុង Chandradeepa Gram Panchayat នៅក្នុងស្រុក Jamtara នៃខេត្ត Jharkhand គណៈកម្មាធិការមួយដែលមានសមាជិក ៨នាក់ ត្រូវបានតែងតាំងក្នុងពេលនៃកិច្ចប្រជុំ Gram Sabha សម្រាប់គោលបំណងនេះ។ នៅក្នុង Khedbrahma និង Taluka Nirikshan Samiti បានអនុវត្តតួនាទីនេះ ហើយត្រូវបានគាំទ្រដោយ Panchayat Vikas Samiti ។ គណៈកម្មាធិការនេះនឹងដឹកនាំដំណើរការទាំងស្រុងនៃសវនកម្មសង្គម។ ជាមួយគ្នានេះដែរក្រុមតូចៗ ជាងនេះចំនួនបីក្រុមដែល

រួមមានសមាជិកនៃគណៈកម្មាធិការ និងអ្នកស្ម័គ្រចិត្តដទៃៗទៀតគឺត្រូវបានបង្កើតឡើងសម្រាប់ការត្រៀងគរការបញ្ជាក់ទិន្នន័យ និងការបញ្ជាក់កាយសម្បទារបស់ Gram Sabha (PRIA, 2007) ។

៣. **ការសាងសង់សមត្ថភាពសមាជិករបស់គណៈកម្មាធិការៈ** សមាជិកទាំងនេះត្រូវបានគេតម្រង់ទិសដោយសង្ខេបអំពីខ្លឹមសារនៃការគប់គ្រង តម្លាភាព គណនេយ្យភាព និងវិមជ្ឈការ ។ បន្ទាប់មកទៀតពួកគេត្រូវបានតម្រង់ទិសអំពីរបៀបក្នុងការធ្វើសវនកម្មសង្គម ។ ភាគរីដេអូអំពីសវនកម្មសង្គមពីពេលមុនៗត្រូវបានបញ្ចាំងដល់ពួកគេ ហើយការសង្ស័យនានារបស់គេត្រូវបានជ្រះស្រឡះ ។ ក្រៅពីនេះដំណោះស្រាយ និងការជួយសម្រួលជាទៀងទាត់ក៏ត្រូវបានធ្វើឡើងផងដែរ ។

៤. **ការប្រមូល និងការបញ្ជាក់ទិន្នន័យៈ** ព័ត៌មានដែលទាក់ទងទៅនឹងបទបញ្ជា ការចេញប័ណ្ណសម្គាល់ការងារ ប្រាក់ដំណាច់ការងារ ការទូទាត់ផ្សេងៗ ទ្រព្យសម្បត្តិនានាដែលបានបង្កើតឡើងជាដើម គឺត្រូវប្រមូលពីរបាយការណ៍មួយចំនួនដូចជា បញ្ជីសរុប បញ្ជីចុះឈ្មោះ បញ្ជីតម្រូវការ កំណត់ហេតុនៃកិច្ចប្រជុំផ្សេងៗនៃ Gram Sabha និង Gram Panchayats និងពីផ្នែកបច្ចេកទេស និងផ្នែករដ្ឋបាលជាដើម ។ ប្រសិនបើ តម្រូវការនៃការដាក់ពាក្យសុំដែលស្ថិតនៅក្រោមច្បាប់ RTI គឺត្រូវបញ្ជូនទៅដើម្បីសុំព័ត៌មាន ។ បន្ទាប់មកទៀតទិន្នន័យទាំងនេះនឹងត្រូវបញ្ជាក់ពីកន្លែងការងារដែលត្រួតពិនិត្យកាយសម្បទា ហើយនិងការជួបជាមួយបុគ្គលិកដោយផ្ទាល់ ។ ការផ្លាស់ប្តូរអ្វីមួយគឺត្រូវបានកត់ត្រាទុក ហើយឯកសារជាលាយលក្ខណ៍អក្សរដែលបានចុះហត្ថលេខារួច គឺត្រូវប្រមូលទុក ។ បន្ទាប់មកទៀតព័ត៌មានទាំងនេះគឺត្រូវបង្ហាញនៅក្នុងរបាយការណ៍ជាភាសាតាមតំបន់សម្រាប់ការផ្សព្វផ្សាយ ។ អំឡុងពេលនៃការធ្វើសវនកម្មសង្គមនៅក្នុង Khedbrahma Taluka នៅក្នុង Gujarat គេបានដឹងថាព័ត៌មានចាំបាច់ត្រូវផ្តល់ទៅឱ្យប្រជាជនយ៉ាងហោចណាស់ ១៥ថ្ងៃមុនពេល Gram Sabha ដើម្បីងាយស្រួលយល់អំពីភាសា និងពីទម្រង់បែបបទ ។ ការធ្វើបែបនេះគឺផ្តល់ឱកាសឱ្យពួកគេក្នុងការគិត ការពិភាក្សាក្នុងចំណោមខ្លួនពួកគេ ហើយបន្ទាប់មកទៀតបង្កើតជាបញ្ហា និងសំណួរសម្រាប់លើកឡើងនៅក្នុង Gram Sabha ។

៥. **ការត្រៀងគរនៃ** Gram Sabha: Gram Sabha ត្រូវបានហៅដោយ Gram Panchayat ដោយស្របតាមច្បាប់ Panchayti Raj ហើយនិងច្បាប់របស់រដ្ឋ ។ សេចក្តីជូនដំណឹងផ្សេងៗត្រូវបានបិទនៅតាមកន្លែងផ្សេងៗ ហើយវិធីសាស្រ្តតាមបែបបូរាណ ដូចជាការវាយស្គរ គឺត្រូវបានប្រើប្រាស់ ។ រាល់គ្រួសារទាំងអស់នៅក្នុងតំបន់ Gram Panchayat ជាពិសេស គ្រួសារក្រីក្រ និងជនដែលគេមិនរាប់រក គឺត្រូវឱ្យគេដឹងពីកាលបរិច្ឆេទ ទីកន្លែង យុត្តាធិការ និងរបៀបវារៈនៃកិច្ចប្រជុំ ។ គួរតែពន្យល់ដល់សមាជិកផងដែរថា ហេតុអ្វីបានជាសវនកម្មសង្គមមានសារៈសំខាន់សម្រាប់ពួកគេ កិច្ចប្រជុំថ្នាក់ឃុំក៏ត្រូវបានធ្វើឡើងផងដែរ ។ ការជឿជាក់របស់ Gram Sabha

ចំពោះតម្រូវការក្នុងការលើកកម្ពស់ដល់គ្រួសារក្រីក្រ និងគ្រួសារដែលគេមិនរាប់រកគឺថា មិនយូរមិនឆាប់ពួកគេនឹងចូលរួមយ៉ាងសកម្ម។

៦. Gram Sabha: Gram Sabha ជាពិសេសសម្រាប់សវនកម្មសង្គមនេះគឺដឹកនាំ ដោយមនុស្សម្នាក់ដែលមិនបញ្ចូលគ្នាជាមួយនឹងការអនុវត្តនៃ NREGS នោះទេ។ លទ្ធផលជាចំបងនានានៃរបាយកាណ៍គឺត្រូវបានសរសេរនៅលើប័ណ្ណក្រដាស ហើយទុកធ្វើជាព័ត៌មានសម្រាប់សមាជិក។ ប្រធានគណៈកម្មាធិការសវនកម្មសង្គមធ្វើបទបង្ហាញពីរបាយការណ៍ក្នុងភាសាសាមញ្ញ។ ចំពោះប្រជាជន ជាពិសេសអ្នកក្រីក្រ និងជនដែលគេមិនរាប់រកគឺត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរ និងឱ្យធ្វើការរិះគន់ ទៅកាន់ Gram Sabha ប្រសិនបើមាន។ ប្រធាន ក្រុមមន្ត្រី និង ភ្នាក់ងារប្រតិបត្តិការងារគឺនៅតែរក្សាការ ធ្វើបទបង្ហាញ ហើយឆ្លើយសំណួរ ហើយធ្វើការបកស្រាយពីការរិះគន់នានាពីសំណាក់សមាជិកមួយចំនួន ។ ចំពោះដំណោះស្រាយគឺត្រូវវិឆ្លងកាត់ការបោះឆ្នោត។ កំណត់ហេតុត្រូវរៀប ចំដោយមនុស្សម្នាក់ក្រៅ ពីលេខាធិការរបស់ Gram Panchayat បន្ទាប់មកទៀតកំណត់ហេតុទាំងនេះនឹងត្រូវចុះ ហត្ថលេខាដោយសមាជិក គ្រប់រូប ដែលមានវត្តមានចូលរួម។ Gram Sabha ក៏ត្រូវបានប្រើប្រាស់ផងដែរសម្រាប់ ធ្វើឱ្យប្រជាជនយល់ដឹងពីសិទ្ធិ និងនីតិវិធីរបស់ពួកគេ។

៧. **ការតាមដាន :** របាយការណ៍ព្រមទាំងកំណត់ហេតុនៃ Gram Sabha គឺត្រូវចែកចាយទៅរដ្ឋបាលតាមផ្នែកថ្នាក់ស្រុក និង ថ្នាក់រដ្ឋ ហើយព្រមជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ និងគ្រឹះស្ថានអប់រំផងដែរសម្រាប់ការតាមដាន។ សម្ពាធជាប្រចាំលើផ្នែករដ្ឋបាល គឺត្រូវបានរក្សាទុកសម្រាប់សកម្មភាពរាល់ពេលដែលមានការរិះគន់ និងការធ្វើខុសច្បាប់ដែលបានកំណត់នៅអំឡុងពេលនៃសវនកម្មសង្គម។ នៅក្នុង Gram Sabha ខាងក្រោមនេះគឺសម្រាប់សកម្មភាពសវនកម្មសង្គមដែលបានធ្វើត្រូវបានធ្វើបទបង្ហាញដោយផ្នែករដ្ឋបាល។

**ការកកស្ទះសំខាន់ៗ :**

១. ***វិប្បធម៌នៃភាពស្ងៀមស្ងាត់:*** ក្នុងការសម្រួលដល់សវនកម្មសង្គមនៅក្នុង NREGS វិប្បធម៌នៃភាពស្ងៀមស្ងាត់គឺជាផ្នែកមួយនៃការកកស្ទះសំខាន់ៗ ។ ប្រជាជនមិននិយាយចេញទោះបីជាគេឃើញមានកំហុសកើតមានឡើងក៏ដោយ ព្រោះគេគិតថា វាមិនប៉ះពាល់ដល់គេផ្ទាល់នោះទេ។ បញ្ហានេះគឺមួយផ្នែកបណ្តាលមកពីភាពអវិជ្ជា ហើយមួយផ្នែកទៀតបណ្តាលមកពីការពឹងផ្អែក ។ គ្រួសារភាគច្រើនគឺត្រូវបានប៉ះពាល់ផ្ទាល់ដោយ NREGS គឺជាផ្នែកក្រីក្រ ហើយមិនមានគេរាប់រកពីសង្គម និងការភ័យខ្លាចក្នុងការបញ្ចេញសំឡេង ។

២. **ការទប់ទាល់ពីអាជ្ញាធរនានា :** តំរិយាបទគ្រប់គ្រងនៃអ្នកបង្កើតច្បាប់ និងច្បាប់ដែលបានដាក់ចេញ គឺត្រូវបានដាក់សម្ពាធយ៉ាងខ្លាំងខ្លាទៅលើអាជ្ញាធរ ហើយពួកគេទប់ទល់នឹងការខិតខំប្រឹងប្រែងណាមួយ ដែលឱ្យពួកគេទទួលខុសត្រូវ។ ពួកគេក៏មានអារម្មណ៍ភ័យខ្លាចនៃការដាក់ទោសទណ្ឌផងដែរ ប្រសិនបើមានការអនុវត្តខុសឆ្គងអ្វីមួយត្រូវបានរកឃើញអំឡុងពេល នៃការធ្វើសវនកម្មសង្គមនោះ ។ ដូច្នេះគេនាំគ្នាប្រឆាំងនឹងដំណើរការនៃសវនកម្មសង្គម ដោយផ្អែកលើយុត្តាធិការរបស់គេ ។ នៅពេលខ្លះគេក៏ប្រើមធ្យោបាយ ដែលប្រើកម្លាំងផងដែរដើម្បីបង្អាក់ អង្គការសង្គមស៊ីវិល និងសកម្មជនមួយចំនួនដែលជួយសម្រួលដល់ដំណើរការនេះ។ នៅក្នុងស្រុក Jamtara នៃ Jharkhand វាត្រូវបានគេសង្កេតឃើញថា ស្រុក និងមន្ត្រីនានា នៅតាមផ្នែក គឺមិនផ្តល់ព័តិមានដែលត្រូវការសម្រាប់សវនកម្មសង្គមទេ សូម្បីតែទាក់ទងដល់មន្ត្រីថ្នាក់រដ្ឋហើយក៏ដោយ។ នៅក្នុងស្រុក Karauli នៃខេត្ត Rajasthan ប្រធាននៃ Gram Panchayats មួយចំនួនធ្វើការប្រឆាំងយ៉ាងខ្លាំងខ្លាទៅលើសវនកម្មសង្គមដែលសេរី ហើយស្មើភាព ហើយចង់ឱ្យវាដំណើរការទៅតាមមធ្យោបាយរបស់គេ។

៣. **ទំនាស់ផលប្រយោជន៍ខាងសង្គមសេដ្ឋកិច្ច :** សង្គមឥណ្ឌានៅតាមជនបទគឺមិនមែនជាជនជាតិឯកពន្ធនោះទេ ហើយកំពុងតែ មានបញ្ហាលើវណ្ណៈ ជាន់ថ្នាក់ ខ្សែបន្ទាត់យេនឌ័រ ។ ដំណើរការសវនកម្មសង្គមបានយកចិត្តទុកដាក់ពិចារណាលើអត្ថប្រយោជន៍របស់ក្រុមអ្នកទន់ខ្សោយដូចជាអ្នកក្រីក្រ ស្ត្រីនិងជនជាតិភាគតិច ហើយផ្តល់សិទ្ធិអំណាចឱ្យពួកគេទាំងនោះ។ ដូចនេះ ក្រុមអ្នកមានអំណាចដែលប្រឆាំងនឹងដំណើរការបែបនេះ ដើម្បីពង្រីកខាងក្រុមរបស់គេ។ រដ្ឋ និងសង្គមស៊ីវិលមានតួនាទី សំខាន់ក្នុងការធានានូវសុវត្ថិភាព និងសន្តិសុខសម្រាប់ប្រជាពលរដ្ឋដែលដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីសាធារណៈ។

៤. **របាយការណ៍ដែលមិនអាចបញ្ជាក់បាន:** នៅក្នុងរដ្ឋមួយចំនួន ទម្រង់នៃរបាយការណ៍គឺមានសារៈសំខាន់ចំពោះព័តិមានដែលបុគ្គលិកមិនបានដឹង។ ឧទាហរណ៍ នៅក្នុង Orissa ហើយនិង Himachal Pradesh ប័ណ្ណសម្គាល់ការងារ គឺមិនមានតារាងសម្រាប់ប្រាក់ខែ ដែលបើកទៅឱ្យពលករទេ។ គោលបំណងសំខាន់របស់ប័ណ្ណសម្គាល់ការងារ គឺដើម្បីជួយបុគ្គលិកឱ្យបញ្ជាក់អំពីការងាររបស់គេផ្ទាល់ និងសេចក្តីលម្អិតអំពីប្រាក់ខែ។ ព័តិមានដែលបញ្ចូលទៅក្នុងរបាយការណ៍នៅក្នុងកន្លែងមួយចំនួន ត្រូវបានធ្វើឡើងក្នុងលក្ខណៈដែលមិនអាចបញ្ជាក់បានសម្រាប់ពលករដែលចេះអក្សរតិចតួច ហើយមានការ លំបាក សូម្បីការបណ្តុះបណ្តាលអ្នកស៊ើបអង្កេត។ នៅក្នុងឈ្មោះរបស់បុគ្គលិក និងកន្លែងការងារត្រូវបានផ្លាស់ប្តូរ ដោយលេខកូដតាមលំដាប់ (របាយការណ៍បណ្តោះអាសន្ននៃការស្ទង់មតិដែលធ្វើឡើងដោយវិទ្យាស្ថានវិទ្យាសាស្ត្រសង្គម GB Pant ដែលមានឈ្មោះថា Allahabad ក្នុងឆ្នាំ ២០០៧)

៥. **ការចូលរួមកម្រិតទាបនៅក្នុង** Gram Sabha : ការចូលរួមរបស់ប្រជាជនដែលមានកម្រិតទាបនៅក្នុង Gram Sabha គឺជាការកកស្ទះមួយផ្សេងទៀត។ ការមិនឆ្លើយតបទៅនឹងដំណោះស្រាយនានាពីពេលមុនការគ្រប់គ្រង

ដោយអ្នកដែលមានអំណាច ភាពខ្សត់ខ្សោយនៃការពិភាក្សាដែលមានអត្ថន័យ ជាផ្នែកខ្លះនៃបុព្វហេតុដែលធ្វើឱ្យប្រជាជនគិតថា ការចូលរួមនៅ ក្នុង Gram Sabha គឺជាការខ្ជះខ្ជាយពេលវេលា ។

៦. **ការអនុវត្តដែលមានតម្លៃថ្លៃ:** ធនធានហិរញ្ញវត្ថុមួយផ្នែកធំក្រៅពីសម្រាប់ផ្នែកធនធានមនុស្សគឺចាំបាច់ត្រូវតែចំណាយសម្រាប់ការថតរូប ការធ្វើដំណើរ ហើយនិងការគាំទ្រដល់ការគ្រប់គ្រងរបស់គណៈកម្មាធិការ ឬ ក្រុមសវនកម្ម ហើយនិង Gram Sabha ។ ដើម្បីធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព ដំណើរការទាំងមូលត្រូវធ្វើជាបន្តបន្ទាប់ឥតឈប់ឈរដើម្បីឱ្យវាក្លាយជាការអនុវត្តដែលមានតម្លៃថ្លៃ។ បុគ្គលិកដែលជាអ្នកចូលរួមចំណែកជាបឋមនៃគម្រោងនេះ ត្រូវតែទទួលបាន នូវការចំណាយទៅលើប្រាក់ខែរបស់គាត់ប្រសិនបើគាត់ចំណាយពេលនៅក្នុងដំណើរការដើម្បីដឹកនាំប្រជាជនក្នុងការធ្វើសវនកម្មសង្គម។ ហើយថវិកាមួយចំនួនពីកញ្ចប់ថវិការដ្ឋបាល នៃគម្រោងការចាំបាច់ត្រូវបម្រុងទុក សម្រាប់ការសវនកម្មសង្គម ឬសូម្បីតែជាមូលនិធិដាច់ដោយឡែកសម្រាប់សវនកម្មសង្គមជាមួយគ្នា។

## មេរៀនសំខាន់១ :

១. **ការធ្វើយន្តការសម្រាប់សវនកម្មសង្គមនៅក្នុង** NREGS **ដែលអាចធ្វើទៅបាន** :ថ្វីបើសវនកម្មសង្គមនៃរាល់ផែនការទាំងអស់ត្រូវបានគេអនុវត្តនៅក្នុងសាលាក្តីនៃ Gram Panchayat ដោយ Gram Sabha ត្រូវបានគេធ្វើឡើងស្របទៅតាមច្បាប់រដ្ឋធម្មនុញ្ញមាត្រាទី ៧៣ និងច្បាប់របស់ Panchayati Raj នៅតាម រដ្ឋផ្សេងគ្នា ដែលតាមភាពពិតវាមិនកើតមានឡើយ។ ការបម្រុងទុកនៃសវនកម្មរយៈពេល ៦ខែ នៅ NREGA និងគោលការណ៍លំអិតដោយក្រសួងអភិវឌ្ឍជនបទ បានផ្តល់កន្លែងសម្រាប់ឱ្យអ្នករួមចំណែកទាំងអស់ទាមទារ និងធ្វើការចូលរួមក្នុងសវនកម្មសង្គមនៃការអនុវត្ត NREGS។ បើមិនដូច្នេះទេគឺវាផ្ទុយពីរដ្ឋធម្មនុញ្ញ ហើយការដាក់ទណ្ឌកម្មបានធ្វើឱ្យរដ្ឋបាលមានដំណើរការយឺត និងស្ទាក់ស្ទើរ។

២. **ច្បាប់ស្តីពីការទទួលបានព័ត៌មាននៅឆ្នាំ ២០០៥ គឺជាជំនួយយ៉ាងសំខាន់មួយ :** រាល់ឯកសារនិងរបាយការណ៍ដែលស្ថិតនៅក្រោម NREGS គឺស្ថិតនៅក្រោមការពិនិត្យជាមុនរបស់ច្បាប់ RTI។ សម្រាប់សវនកម្មសង្គមនៃភាពដែលទទួលបានព័ត៌មាននៃNREGS គឺចាំបាច់ ហើយជាមួយនឹងការចូលជាធរមាននៃច្បាប់ RTI អាជ្ញាធរមិនអាចបដិសេធឡើយ ។ ការទទួលបានសិទ្ធិសម្រាប់ច្បាប់សារព័ត៌មានបានចាប់ផ្តើមជាផលមិនល្អមួយនៃការខំប្រឹងប្រែង ដើម្បីផ្តល់នូវតួនាទីរួម។ មុននឹងធ្វើច្បាប់ RTI សាធារណៈជនមិនអាចមើលបញ្ជីបូកសរុបដើមបានឡើយ។ គេក៏ពិនិត្យឃើញដែរថាមាន ភាពភ័យខ្លាចចំពោះកាធ្វើទារុណកម្ម ប្រសិនបើពួកគេមិនផ្តល់ព័ត៌មានបន្ទាប់ពីដាក់ពាក្យសុំ។ មន្ត្រីគឺត្រូវផ្តល់ព័ត៌មានមុនពេលដាក់ពាក្យសុំ។

៣. **សវនកម្មសង្គមបង្កប់នូវន័យលាក់កំបាំង :** សវនកម្មសង្គមបង្កើតឱ្យមានភាពភ័យខ្លាច និងភាពអាក់អន់ចិត្តនៅក្នុងចំណោមអ្នកតំណាងដែលជ្រើសរើស ជាពិសេសប្រធាន។ នៅតំណាក់កាលដំបូង ប្រសិនបើសវនកម្មសង្គមត្រូវបានគេលើកឡើងច្រើនដូចជាដំណើរការសិក្សាដែរ ដើម្បីបញ្ចូលទៅក្នុងវប្បធម៌នៃតម្លាភាព និងភាពទទួលខុសត្រូវប្រសើរជាងការស្វែងរកកំហុស វាងាយស្រួលជាងក្នុងការនាំឱ្យប្រធានធ្វើការងារ។ នៅ Gujarat សូម្បីតែមន្ត្រីរដ្ឋាភិបាលក៏អាចត្រូវបានគេភ្ជាប់ទៅនឹងគម្រោងនៃដំណើរការអប់រំនេះដែរ។ ជោគជ័យបន្ថែមដ៏តូចមួយនឹងជំរុញឱ្យប្រជាជនមានភាពជឿទុកចិត្ត និងសីលធម៌ល្អ ជាពិសេសគឺជនក្រីក្រ និងជនដែលគេមិនរាប់រក។

៤. **ការជួយសម្រួលពី CSO ធ្វើឱ្យសវនកម្មសង្គមកាន់តែមានប្រសិទ្ធភាព :** សវនកម្មសង្គមត្រូវការការជួយសម្របសម្រួល និងធ្វើការប្រមូលផ្តុំជាច្រើន ដូចច្នេះហើយទើបវាបានធ្វើទំនាក់ទំនងជាមួយនឹង CSO ដើម្បីឱ្យដំណើរការ

កាន់តែមានប្រសិទ្ធភាព។ ដោយសារតែពួកគេមិនមានទំនាក់ទំនងជាមួយនឹងការប្រតិបត្តិការងារ វាបានពង្រឹងនូវវត្ថុវិស័យភាព និងភាពជឿជាក់។ សូម្បីតែក្នុងចំណោមសមាជិកនៃ Gram Sabha សង្គមស៊ីវិលមានភាពដែលអាចទទួលយកបានច្រើនជាងភ្នាក់ងាររដ្ឋាភិបាល ។ ទោះបីជាយ៉ាងណាក៏ដោយសម្រាប់ជំនាញការជាក់លាក់ត្រូវការការសម្របសម្រួលរបស់ CSO ប្រកបដោយប្រសិទ្ធភាពផងដែរ ។

៥. **រដ្ឋបាលថ្នាក់ស្រុកដែលមានការលើទឹកចិត្ត ធ្វើដំណើរការមានភាពរលូនៈ** រដ្ឋបាលថ្នាក់ស្រុកដែលស្និទ្ធស្នាលជាមួយនឹងប្រជាជន ជាពិសេសសាលាក្តីថ្នាក់ស្រុក ធ្វើឱ្យមានភាពខុសគ្នាយ៉ាងច្រើនក្រោមលក្ខខណ្ឌនៃការធ្វើឱ្យដំណើរការមានភាពរលូន ដែលធ្វើឱ្យរដ្ឋបាលតាមផ្នែក និងតាមភូមិមានការឆ្លើយតប ហើយធ្វើជាគំរូសម្រាប់តាមដានសកម្មភាពនានានៃលទ្ធផលរបស់សវនកម្មសង្គម។ នៅក្នុងស្រុក Ananthpur (Andhra Pradesh), Dungarpur (Rajasthan), Chamba (Himachal Pradesh), Ranchi និង Pakur (Jharkhand) សាលាក្តីថ្នាក់ស្រុកនានាគឺជាការរួមចំណែកយ៉ាងសំខាន់សម្រាប់សវនកម្មសង្គមជោគជ័យនៅក្នុង Gram Panchayats ដែលបានជ្រើស រើស (CEC 2006, PRIA 2007) ។

៥. **វិធានការទាន់ពេលវេលាដោយអាជ្ញាធរមានសមត្ថកិច្ចស្តីពីការរកឃើញថា មានផលប៉ះពាល់ទៅលើសវនកម្មសង្គមសម្រាប់ដំណាក់កាលបន្ទាប់ :** តាំងពីពេលដែលសវនកម្មសង្គមរបស់ NREGS បានធ្វើឡើងរៀងរាល់ ៦ខែម្តង វិធានការទាន់ពេលវេលាស្តីពីសវនកម្មសង្គមដំបូង បានជួយជំរុញប្រជាពលរដ្ឋ និងជួយសម្រួលដល់អង្គការមួយចំនួន។ ផ្ទុយមកវិញ ប្រសិនបើវាមិនកើតឡើងទេនោះ ប្រជាជនមានការមិនសប្បាយចិត្ត និងមិនបានចូលរួមនោះទេ។ វិធានការដែលបានចាត់នៅ Dungarpur, Sarguja និង Ranchi មិនត្រឹមតែជំរុញការអនុវត្ត NREGS ប៉ុណ្ណោះទេ តែថែមទាំងលើកទឹកចិត្តអង្គការសង្គមស៊ីវិល និងប្រជាជនឱ្យរៀបចំសវនកម្មសង្គមបន្ថែមទៀត។ អភិបាលរងនៃ Ranchi បានផ្អាកការងារមន្ត្រីចំនួន១៦ នាក់ ហើយ FIR ត្រូវបានដាក់ធ្វើឡើងចំពោះមន្ត្រីប្រាំនាក់

ដែលទទួលនូវប្រាក់កម្រៃជើងសារខុសច្បាប់ បង្កើតមូលនិធិដែលមិនសមស្រប ហើយរាយការណ៍ដោយមិនមានចុះផ្ទាល់ទៅដល់មូលដ្ឋាន។ សកម្មភាពទាំងនេះត្រូវបានចាត់ចែងក្នុងរយៈពេលបីថ្ងៃចាប់ពីថ្ងៃជំនុំជម្រះជាសាធារណៈត្រូវបានធ្វើឡើងដែលជាផ្នែកមួយនៃសវនកម្មសង្គម។

នៅក្នុង Andhra Pradesh ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានប្រគល់ត្រឡប់មកវិញដោយមន្ត្រីពុករលួយ ដោយសារតែដំណើរការរបស់សវនកម្មសង្គមដែលបានធ្វើឡើងនៅក្នុងស្រុកចំនួន ១៣ ។ អំពើពុករលួយនៅក្នុងអង្គភាពប្រៃសណីយ៍ (ប្រធានអង្គភាពប្រៃសណីយ៍ធ្លាប់យកលុយមួយចំនួនពីគណនីរបស់បុគ្គលិកដែលប្រាក់ខែរបស់គេបើកតាមការិយាល័យប្រៃសណីយ៍) នៅពេលនេះត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័ស។

៧. **សវនកម្មសង្គមទទួលបាននូវផលប្រយោជន៍ជាច្រើនដូចជា ការយល់ដឹង ការចុះឈ្មោះ និងសេចក្តីត្រូវការមានការកើនឡើង:** អំឡុងពេលនៃដំណើរការនៃការប្រមូលទិន្នន័យ ការបញ្ជាក់ និង ការផ្ទៀងផ្ទាត់នៃ Gram Sabha គណៈកម្មាធិការ និងអ្នកស្ម័គ្រចិត្តទំនាក់ទំនងជាមួយប្រជាជនដោយផ្ទាល់ ហើយចែកចាយឱ្យពួកគេនូវបទបញ្ញត្តិនៃច្បាប់ ការទទួលបានសិទ្ធិ និងនីតិវិធីរបស់គេ។ គ្រួសារដែលមានចំណាប់អារម្មណ៍ត្រូវបានលើកទឹកចិត្តដាក់ពាក្យសុំចុះឈ្មោះ ហើយក៏ចំពោះតម្រូវការការងារផងដែរ។ ការរកឃើញជាបណ្តោះអាសន្ននៃការសិក្សារបស់ធនាគារពិភពលោកអំពីផលប៉ះពាល់ទៅលើសវនកម្មសង្គមនៅក្នុង Andhra Pradesh បានបង្ហាញថា ការយល់ដឹងរបស់ប្រជាជនអំពី NREGA បានកើនឡើងពី ៣៩%ទៅដល់ ៩៨%។ ការយល់ដឹងពីរបៀបនៃការគណនាលើប្រាក់ខែ និងប្រព័ន្ធបើប្រាក់ខែរបស់គេដែលស្ថិតនៅក្រោម NREGA មានសំទុះពី ៦២% ដល់ ៩១%។

## សេចក្តីសន្និដ្ឋាន:

ការយល់ដឹងដែលកើនឡើងនៃតម្រូវការសម្រាប់តម្លាភាព គណនេយ្យភាព ហើយនិងការចូលរួមបាននាំឱ្យមានការបង្កើតឱ្យមានចន្លោះសម្រាប់សវនកម្មសង្គមដែលស្ថិតនៅក្រោម NREGA ។ ចំពោះការប្រើប្រាស់ការបង្កើតគ្រឹះស្ថាននេះបានធ្វើឱ្យភ្នាក់ងាររបស់រដ្ឋាភិបាល និងភ្នាក់ងារក្រៅរដ្ឋាភិបាលជាច្រើនបង្កើតនូវសវនកម្មសង្គមនៅក្នុងរយៈពេលមួយឆ្នាំកន្លះចុងក្រោយ ចាប់តាំងពីការចេញដំណើរការរបស់ NREGS បើទោះបីជាប្រើប្រាស់វិធាន និងវិធីសាស្ត្រខុសគ្នាក៏ដោយ។

ការចូលរួមក្នុងចំនួនយ៉ាងច្រើនពីសំណាក់អង្គការសង្គមស៊ីវិលនៅក្នុងសវនកម្មសង្គមនឹងបង្កើតឱ្យមានការប៉ះទង្គិចទៅលើទំនាក់ទំនងរវាងអង្គការក្នុងក្របខ័ណ្ឌរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនាពេលអនាគតដែលពេលបច្ចុប្បន្ននេះវាបានផ្លាស់ប្តូរនូវបញ្ហានៃការខ្វែងគំនិតគ្នា ឱ្យទៅជាមានការសម្រុះសម្រួលរវាងគ្នានឹងគ្នា។ ដោយការមើលរៀងៗខ្លួនទៅលើគោលនយោបាយដែលបានដាក់ចេញដោយរដ្ឋាភិបាលឥណ្ឌា ទៅលើផ្នែកស្ម័គ្រចិត្តដែលជាការគាំទ្រ ដែលគេទទួលស្គាល់ព្រមទាំងតួនាទីយ៉ាងសំខាន់នៃផ្នែកស្ម័គ្រចិត្ត ហើយការប៉ះពាល់នេះទាមទារឱ្យធ្វើការសិក្សានៅពេលក្រោយ។

វាត្រូវបានគេសង្កេតឃើញថា បើគ្រាន់តែសិក្សាទៅលើបទបញ្ញត្តិដែលបានចែង គឺមិនមានប្រសិទ្ធផលទេក្នុងការបង្កើនតម្លាភាព និងគណនេយ្យភាពនៅក្នុង NREGA ។ នៅក្នុងផ្នែកដែលមានតម្រូវការ ចាំបាច់ត្រូវពង្រឹងនូវការយល់ដឹងអំពីការទទួលបានសិទ្ធិ ការកសាងសមត្ថភាព ការគៀងគរ និងការជួយសម្រួល។ ផ្នែកផ្គត់ផ្គង់ដែលទទួលខុសត្រូវជាបឋមទៅលើការតាមដានសកម្មភាព គួរត្រូវបានទ្រទ្រង់ដោយការបង្កើតនូវបរិស្ថានដែលមិនមានការគំរាមកំហែង ការកសាងសមត្ថភាពក្នុងការរក្សាទុករបាយការណ៍។ វាក៏មានសារៈសំខាន់ផងដែរក្នុងការបំពេញនូវដំណើរការនៃការបែងចែកសិទ្ធិអំណាចទៅឱ្យ Panchayats ពីព្រោះគណនេយ្យភាពដែលមិនមានអំណាច គឺមិនខុសពីអំណាចដែលគ្មានគណនេយ្យភាពទេ។

**References:**

Government of India, (2005), National Rural Employment Guarantee Act.

Minsitry of Rural Development, Government of India, (2006) Central Operational Guidelines on NREGA.

Planning Commission of India, (2005), Social Audit: Gram Sabha and Panchayati Raj, New Delhi.

Unnati, (2007) Social Audit in Khedbrahma Taluka of Sabarkantha, Unpublished document, Ahmedabad.

PRIA, (2007), Biannual Report April- September 2007, Unpublished document, New Delhi.

Centre for Environment Concern (CEC) (2006), Report of Social Audit in Ananthpur District of Andhra Pradesh, Unpublished document, Hyderabad.

Arora, Subhash C, (2003) 'Good Governance And Panchayati Raj' in C.P.Barthwal's edited book "Good Governance in India", Deep and Deep Publications, New Delhi.

Babu, D. Shyam, (2004), 'Social Sector Schemes: A Brief Review' in Bibek Debroy's edited book "Agenda for Improving Governance" Academic Foundations, New Delhi.

Das, Vidhya and Pramod Pradhan, (2007), 'Illusions of Change' Economic and Political Weekly, Vol. XLII No 32 August.

Godbole, Mahadev,( 2003) "Public Accountability and Transparency: Imperatives of Good Governanace", Orient Longman, New Delhi.

Source: Sinha, R.K. (2008), Accountability in Employment Programmes: Case of Social Audit in NREGA, Participation and Governance, Citizenship DRC Special Issue, Volume 1 No 1, January pp – 79-93